# ៣) អនុសាសន៍ និងជំហានបន្ទាប់

ដើម្បីថែរក្សាកេរដំណែលរបស់ អ.វ.ត.ក. និងពង្រឹងសមត្ថភាពរយៈពេលវែងរបស់កម្ពុជាក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ កម្មវិធីក្រោយការបញ្ចប់របស់ អ.ត.វ.ក. គួរតែអនុវត្តសកម្មភាពដូចតទៅ៖

**បង្កើតប្រព័ន្ធសេវាកម្មផ្សេងៗគាំទ្រដល់ជនរងគ្រោះ៖**

លើកកម្ពស់ការទទួលបានការថែទាំសុខភាពដែលមានការឧបត្ថម្ភធន គម្រោងជំនួយសង្គម និងជំនួយពាក់ព័ន្ធនឹងអត្តសញ្ញាណស្របច្បាប់ក្នុងចំណោមអ្នករស់រានមានជីវិតតាមរយៈការសម្របសម្រួលជាមួយក្រសួងសង្គមកិច្ច ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ ដើម្បីបង្កើនការព្យាបាលជំងឺរ៉ាំរ៉ៃ ការគាំទ្រជីវភាពរស់នៅ និងសាមគ្គីភាពសង្គម ជាពិសេសសម្រាប់អ្នករស់រានមានជីវិតមានវ័យចំណាស់ ជាស្ត្រីមេម៉ាយ និងគ្រួសារដែលប្រឈមនឹងហានិភ័យ។

**បង្កើនកិច្ចសន្ទនាសហគមន៍ និងវេទិកាកសាងទំនុកចិត្ត៖**

សហការជាមួយអាជ្ញាធរមូលដ្ឋាន អ្នករស់រានមានជីវិត និងសហគមន៍ជនជាតិភាគតិច ដើម្បីបង្កើតវេទិកាសន្ទនា និងបណ្តាញទំនាក់ទំនងដែលលើកកម្ពស់ការយល់ដឹងអំពីតម្រូវការរបស់ជនជាតិភាគតិច កាត់បន្ថយភាពតានតឹង និងពង្រឹងសមត្ថភាពផ្តល់សញ្ញាអាសន្នជាមុនក្នុងសហគមន៍។

**ពង្រឹងក្របខណ្ឌ និងយន្តការថ្នាក់ជាតិទប់ស្កាត់អំពើឃោរឃៅ៖**

បញ្ចូលទស្សនៈ និងបរិយាបន្នជនជាតិភាគតិច ទៅក្នុងក្របខណ្ឌច្បាប់ និងគោលនយោបាយជាតិស្តីពីការទប់ស្កាត់អំពើឃោរឃៅ ដើម្បីពង្រឹងភាពធន់របស់កម្ពុជាប្រឆាំងនឹងអំពើឃោរឃៅនាពេលអនាគត រួមទាំងការជំរុញសមត្ថភាពរបស់អ្នកតំណាងទទួលបន្ទុកកិច្ចការ R2P និងពិចារណាលើការរួមចំណែក អាណត្តិ និងតួនាទីរបស់ស្ថាប័នកេរដំណែលថ្មីរបស់ អ.វ.ត.ក. ក្នុងការទប់ស្កាត់អំពើឃោរឃៅ។

**រក្សាការចងចាំ និងពង្រឹងការសិក្សាពីការទប់ស្កាត់អំពើឃោរឃៅ៖**

បន្តចងក្រងឯកសារស្តីពីអំពើឃោរឃៅពីអតីតកាលប្រឆាំងនឹងជនជាតិភាគតិចរក្សាសក្ខីកម្ម និងបទពិសោធន៍របស់សហគមន៍ និងកំណត់អត្តសញ្ញាណមេរៀនដែលយើងអាចរៀនសូត្រ បានមុនពេលវាបាត់បង់។ បញ្ចូលស្នាដៃទាំងនេះទៅក្នុងការអប់រំថ្នាក់ជាតិ កម្មវិធីបណ្តុះបណ្តាល និងយុទ្ធសាស្ត្រទប់ស្កាត់អំពើឃោរឃៅ ដើម្បីធានាបាននូវការរៀនសូត្រ និងការយល់ដឹងអន្តរជំនាន់។

## ឯកសារយោង


United Nations, Responsibility to Protect (R2P): 2005 World Summit Outcome Document (A/RES/60/1, 24 October 2005): https://www.un.org/en/development/desa/population/migration/generalassembly/docs/globalcompact/A_RES_60_1.pdf

United Nations, Framework of Analysis for Atrocity Crimes. Office on Genocide Prevention and the Responsibility to Protect (2014): https://www.un.org/en/genocideprevention/documents/publications-and-resources/Genocide_Framework%20of%20Analysis-English.pdf

United Nations. Responsibility to Protect: The Commitment to Prevent and Protect Populations from Atrocity Crimes' (A/78/901, 3 June 2024): https://docs.un.org/en/A/78/901

'Joint Study on the Contribution of Transitional Justice to the Prevention of Gross Violations and Abuses of Human Rights and Serious Violations of International Humanitarian Law', Report of the Special Rapporteur on the promotion of truth, justice, reparation and guarantees of non-recurrence and the Special Adviser to the Secretary-General on the Prevention of Genocide, UN doc. A/HRC/37/65 (6 June 2018).

Global Network for R2P Focal Points (2024) 'Manual for R2P Focal Points', Global Centre for the Responsibility to Protect, <https://www.globalr2p.org/wp-content/uploads/2024/02/R2P-Focal-Points-Manual-6-Feb-2024-FINAL.pdf>


**បន្ទាន់**

ដោយអ្នករស់រានមានជីវិតកំពុងបាត់បង់ជីវិតជារៀងរាល់ខែ សកម្មភាពជាបន្ទាន់ពិតជាចាំបាច់ដើម្បីការពារសិទ្ធិរបស់ពួកគេ រក្សាទុកការចងចាំ និងធានាថា សមិទ្ធផលរបស់ អ.វ.ត.ក. ត្រូវបានប្រែក្លាយជាគ្រោងការណ៍មួយដែលជាប់លាប់ក្នុងការការពារដោយផ្តោតលើសហគមន៍សម្រាប់អនាគតរបស់កម្ពុជា។


ផលិតដោយ

អង្គការនារីដើម្បីសន្តិភាព WOMEN PEACE MAKERS organization

គាំទ្រដោយ

កិច្ចសហប្រតិបត្តិការ អាល្លឺម៉ង់ DEUTSCHE ZUSAMMENARBEIT

Implemented by giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

Ziviler Friedensdienst Civil Peace Service






# ពីយុត្តិធម៌ឈាន ទៅការទប់ស្កាត់

## លើកកម្ពស់ប្រសិទ្ធិភាពនៃការទប់ស្កាត់អំពើឃោរឃៅដោយស្តាប់សំឡេង អ្នករស់រានមានជីវិតជាជនជាតិភាគតិចក្រោយការបញ្ចប់អាណត្តិអ.វ.ត.ក.

# ១ កាលប្រវត្តិ និង ហេតុផលនៃការសិក្សា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) បានផ្តល់ឲ្យមានការទទួលខុសត្រូវតាមច្បាប់ជាប្រវត្តិសាស្ត្រចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងអំឡុងរបបខ្មែរក្រហម។ នៅពេលដែល អ.វ.ត.ក. បានបញ្ចប់កិច្ចការជំនុំជម្រះរបស់ខ្លួន និងបិត ក្នុងតំណាក់កាលបំពេញកិច្ចការដែលនៅសេសសល់កម្ពុជាបាន មកដល់ដំណាក់កាលក្រោយ អ.វ.ត.ក. ដែលកេរដំណែលរបស់តុលាការនេះ ត្រូវឈានទៅរកជំហានថ្មី ក្នុងការទប់ស្កាត់រាល់ឧក្រិដ្ឋកម្មឃោរឃៅនៅថ្ងៃអនាគត និងរក្សាឲ្យបានខ្ជាប់ខ្ជួននូវពាក្យថា "មិនត្រូវឲ្យអំពើទាំងនោះកើតមានជាថ្មីម្តងទៀត" មកលើប្រជាជនកម្ពុជានាជំនាន់ក្រោយៗទេ។

សាលក្រម និងការផ្តន្ទាទោសរបស់ អ.វ.ត.ក. បានបង្ហាញពីគោលនយោបាយ និងផែនការរើសអើងដោយរបបខ្មែរក្រហមលើជនជាតិ ភាគតិច រួមទាំងបានកំណត់មុខសញ្ញាធ្វើបាបកាប់សម្លាប់ និងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ លើក្រុមជនជាតិផ្សេងៗ ក្រុមជាតិសាសន៍ដទៃ និងក្រុមសាសនានានានៅទូទាំងប្រទេស។ ហេតុដូចនេះហើយ ការទប់ស្កាត់កុំឲ្យមានអំពើឃោរឃៅបៀបនេះនៅថ្ងៃអនាគត តម្រូវឲ្យមានការទទួលខុសត្រូវលើសពីនេះថែមទៀត។ វាតម្រូវឲ្យមានសំណងប៉ះប៉ូវលើរបួសស្នាម និងការលើកដំកើងភាពថ្លៃថ្នូរ សុខមាលភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរួមមានទាំងក្រុមជនជាតិ និងក្រុមសាសនាផ្សេងៗផងដែរ។ គោលនយោបាយទាំងនោះត្រូវធានាថា ជនជាតិភាគតិចមិនត្រូវបានគេទុកចោលដោយមិនទទួលបានការការពារ ការទទួលស្គាល់ និងការប្រើប្រាស់សេវាជាតិនានាទេ។ ដើម្បីទប់ស្កាត់អំពើឃោរឃៅទាំងនោះកុំឲ្យកើតមាននៅថ្ងៃអនាគត វាពិតជាចាំបាច់ណាស់ ដែលត្រូវបញ្ចូលខ្លឹមសារនៃវិធានការទប់ស្កាត់ទៅក្នុងច្បាប់ រចនាសម្ព័ន្ធ និងយន្តការនានារួមទាំងកិច្ចសហការពីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។

អង្គការនារីដើម្បីសន្តិភាពបានធ្វើការងារជាច្រើនដូចជា គាំទ្រលើកកម្ពស់សិទ្ធិស្ត្រី និងយុវជនជនជាតិភាគតិចក្នុងគោលបំណងបំប្លែងទំនាស់ និងទប់ស្កាត់អំពើហិង្សា។ ប៉ុន្មានឆ្នាំថ្មីៗនេះ យើងបានធ្វើការងារជាមួយសហគមន៍ខ្មែរក្រោម និងសហគមន៍ជនជាតិភាគតិចវៀតណាមនៅកម្ពុជា ដែលបានឆ្លងកាត់ការជម្លៀសដោយបង្ខំ ការបង្ខំឲ្យធ្វើការ ការសម្លាប់ និងការបដិសេធអត្តសញ្ញាណរបស់ពួកគេនៅក្នុងរបបខ្មែរក្រហម។

សមាជិកជាច្រើននៃសហគមន៍នេះ បានចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងដំណើរការរបស់ អ.វ.ត.ក. ដែលបង្ហាញពីជំហានសំខាន់មួយឆ្ពោះទៅរកការទទួលស្គាល់ និងស្វែងរកយុត្តិធម៌។ ទោះជាយ៉ាងណាក្តី ជនរងគ្រោះវ័យចំណាស់ទាំងនេះ និងក្រុមគ្រួសារពួកគាត់ទទួលបាននូវការគាំទ្រតិចតួចណាស់នៅដំណាក់កាលបន្ទាប់ពីសវនាការនៃអ.វ.ត.ក. ក្នុងការជួយដោះស្រាយជីវភាពដ៏លំបាកដែលពួកគេកំពុងជួបប្រទះក្នុងពេលបច្ចុប្បន្ន បញ្ហារើសអើង និងភាពងាយរងគ្រោះរបស់ពួកគាត់។ យើងត្រូវការការរៀបចំផែនការដែលរចនាឡើងដោយល្អិតល្អន់ម៉ត់ចត់ និងវិធីសាស្ត្ររួម ដើម្បីជួយបំពងសម្លេងរបស់ពួកគាត់ឲ្យបានកាន់តែឮថែមមួយកម្រិតទៀត និងជួយគាំទ្រជនរងគ្រោះ ព្រមទាំងទប់ស្កាត់អំពើឃោរឃៅ នៅតំណាក់កាលក្រោយ អ.វ.ត.ក.។

### ហេតុអ្វីត្រូវមានព្រឹត្តិបត្រនេះ ?

ការបញ្ចប់ការងាររបស់ អ.វ.ត.ក. មិនមែនមានន័យថាកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់អំពើឃោរឃៅនឹងត្រូវបញ្ចប់នោះទេ។ ប៉ុន្តែផ្ទុយទៅវិញ វាតម្រូវឲ្យមានការប្រុងប្រយ័ត្នបន្តទៀតដើម្បីទប់ស្កាត់កុំឲ្យមានការរំលោភបំពានទៅថ្ងៃអនាគត។ ជនរងគ្រោះទាំងនោះ ជាពិសេស អ្នករស់រានមានជីវិតជាជនជាតិភាគតិច នៅតែរៀបរាប់ប្រាប់យើងពីការរើសអើង ការផាត់ចោលពីសង្គម ភាពក្រីក្រ ការប៉ះទង្គិចផ្លូវចិត្ត និងភាពមិនស្មើគ្នាក្នុងការទទួលបានសញ្ជាតិ និងប្រើប្រាស់សេវាសាធារណៈ និងការការពារតាមរយៈយន្តការរបស់រដ្ឋ។ ទាំងអស់នេះជាកត្តាហានិភ័យដែលបង្កឲ្យកើតមានការប្រព្រឹត្តអំពើហិង្សាយ៉ាងសាហាវកាលពីអតីតកាលរួចមកហើយ។

ព្រឹត្តិបត្រនេះ ឆ្លុះបញ្ចាំងពីភាពងាយរងគ្រោះ និងហានិភ័យនានាដែលនៅតែមាន ហើយសួរថា តើគួរមានសកម្មភាពរួមគ្នាបែបណា ក្នុងការការពារគ្រោះថ្នាក់ទាំងនោះ រួមទាំងសកម្មភាពជាក់ស្តែងនានា ដែលរដ្ឋាភិបាល និងសង្គមស៊ីវិលអាចអនុវត្តទៅបាន នៅតំណាក់កាលក្រោយ អ.វ.ត.ក.។

## សារគន្លឹះ

យុត្តិធម៌តែមួយមុខមិនគ្រប់គ្រាន់នោះទេ។ ការទប់ស្កាត់អំពើឃោរឃៅទាមទារឲ្យមានការប្រុងប្រយ័ត្នជាប់ជានិច្ច ការស្តាប់ និងការគាំទ្រអ្នករស់រានមានជីវិត រួមទាំងអ្នករស់រានមានជីវិតជាជនជាតិភាគតិច ដែលបានទទួលផលប៉ះពាល់ពីអំពើហិង្សា និងស្វែងរកវិធានការជាក់លាក់នានា ព្រមទាំងកំណែទម្រង់សម្រាប់ការទប់ស្កាត់អំពើទាំងនោះ។

## ២ អ្វីនៅជាការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ?

គោលគំនិតនៃពាក្យថា “ឧក្រិដ្ឋកម្មឃោរឃៅ” ត្រូវបានប្រើប្រាស់សំដៅលើ ឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ជាពិសេស ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ សំដៅលើការទប់ស្កាត់នូវរាល់ឧក្រិដ្ឋកម្មអន្តរជាតិទាំងអស់នេះ។

ការទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅទទួលបានការចាប់អារម្មណ៍កាន់តែខ្លាំងបន្ទាប់ពីសហគមន៍អន្តរជាតិបរាជ័យក្នុងការទប់ស្កាត់ ឬបញ្ឈប់នូវឧក្រិដ្ឋកម្មមហាប្រល័យជាច្រើននៅអំឡុងទសវត្សរ៍ឆ្នាំ៩០ ឧទាហរណ៍ដូចជានៅប្រទេសរ៉ូវ៉ាន់ដាជាដើម។ ព្រឹត្តិការណ៍ទាំងនេះ ធ្វើឲ្យមានការប្តេជ្ញាចិត្តជាសាកលដើម្បីទប់ស្កាត់ និងឆ្លើយតបទៅនឹងអំពើឃោរឃៅជាច្រើនដោយអនុម័តនូវវិធាន “កាតព្វកិច្ចក្នុងការការពារ” ឬក៏ហៅកាត់ថា (R2P) ដោយរដ្ឋជាសមាជិកអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ២០០៥។ វិធាននេះ បញ្ជាក់ថា រដ្ឋាភិបាលនីមួយៗ មានកាតព្វកិច្ចចម្បងក្នុងការការពារពលរដ្ឋរបស់ខ្លួន ពីអំពើឃោរឃៅនានា។ R2P ផ្តោតលើការទប់ស្កាត់ជាមុន តាមរយៈការកំណត់សញ្ញាណហានិភ័យនានា ការផ្តល់សញ្ញាទុកជាមុន ការកសាងសមត្ថភាព និងការដោះស្រាយឲ្យចំប្រភពបញ្ហា ដែលនាំឲ្យមានជម្លោះ និងអនុវត្តវិធានការទប់ស្កាត់ រួមមានការបង្កើនចំណេះដឹង និងការលើកកម្ពស់ការយល់ដឹងសាធារណៈ។

កម្ពុជា បានទទួលស្គាល់ថា ឧក្រិដ្ឋកម្មឃោរឃៅនានា ជាអំពើខុសច្បាប់ដោយបានធ្វើសច្ចាប័នលើច្បាប់អន្តរជាតិជាច្រើន ដូចជាកម្ពុជាចូលជាសមាជិកនៃសន្ធិសញ្ញាទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ហើយកម្ពុជាបានបញ្ចូលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងក្រមព្រហ្មទណ្ឌរបស់ខ្លួន។ លើសពីនេះ កម្ពុជាក៏បានអនុម័តសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗជាច្រើន ដែលតម្រូវឲ្យកម្ពុជាមានកាតព្វកិច្ចបន្ថែមទៀត ក្នុងការការពារការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ និងទ្រង់ទ្រាយធំ។ កាតព្វកិច្ចការពារសិទ្ធិមនុស្សទាំងនោះ បានដាក់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញកម្ពុជាក្នុងមាត្រា៣១។ លើសពីនេះ ដើម្បីជំរុញការអនុវត្តប្រកបដោយប្រសិទ្ធិភាព កម្ពុជាក៏បានតែងតាំងតំណាងថ្នាក់ជាតិម្នាក់ឲ្យធ្វើការទាក់ទងនឹង R2P ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងក្នុងការការពារទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរក្នុងស្រុក។

## ៣ ការស្តាប់ពីអ្នករស់រានមានជីវិត៖ មហន្តរាយ និងហានិភ័យដែលនៅតែមាន

មានដើមបណ្តឹងរដ្ឋប្បវេណីរាប់ពាន់នាក់ត្រូវបានទទួលស្គាល់ដោយ អ.វ.ត.ក. ក្នុងចំណោមពួកគេជា ស្ត្រី មនុស្សវ័យចំណាស់ និងជាសហគមន៍ជនជាតិភាគតិច ដែលរងផលប៉ះពាល់ពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អំពើប្រល័យពូជសាសន៍ ការធ្វើទុក្ខបុកម្នេញសាសនា និងការបង្ខំឲ្យចាកចេញពីទីលំនៅឋាន។ ជនរងគ្រោះជាជនជាតិភាគតិច រួមមានសហគមន៍ជនជាតិចាម និងសហគមន៍មូស្លីម ជនជាតិភាគតិចវៀតណាមនៅកម្ពុជា និងស្ត្រី ព្រមទាំងអ្នកមានវ័យចំណាស់ជាជនជាតិខ្មែរក្រោម។ ក្រុមទាំងនេះធ្លាប់ជាគោលដៅដែលខ្មែរក្រហមធ្វើបាបក្នុងសម័យខ្មែរក្រហម ហើយពួកគាត់មួយចំនួននៅតែជួបប្រទះការរើសអើង និងការផាត់ចេញពីសង្គមរហូតដល់សព្វថ្ងៃនេះ។

នៅឆ្នាំ ២០២៤ អង្គការនារីដើម្បីសន្តិភាព បានធ្វើការសម្ភាសជាមួយប្រជាជនខ្មែរក្រោម និងជនជាតិវៀតណាមចំនួន៨៧នាក់។ ពួកគាត់ទាំងអស់សុទ្ធតែជាដើមបណ្តឹងរដ្ឋប្បវេណី និងជាសមាជិកគ្រួសាររបស់ដើមបណ្តឹង ឬក៏ជាសមាជិកមកពីសហគមន៍របស់ពួកគេ។ ដើមបណ្តឹងមួយចំនួនបានបាត់បង់ជីវិតទៅហើយ និងមានដើមបណ្តឹងជនជាតិភាគតិចវៀតណាមជាច្រើនបានផ្លាស់ទីលំនៅ តាមបណ្តោយបឹងទន្លេសាបដែលជាហេតុធ្វើឲ្យយើងមិនអាចរកពួកគាត់ឃើញទេ។

អ្នករស់រានមានជីវិតបានពិពណ៌នាថា ការងាររបស់ អ.វ.ត.ក. រួមទាំងការចូលរួមរបស់ពួកគាត់មានអត្ថន័យ ប៉ុន្តែមិនទាន់ពេញលេញ។ អ្នករស់រានមានជីវិតម្នាក់បាននិយាយថា៖ “យុត្តិធម៌បានមកមែន ប៉ុន្តែបន្ទាប់មកក៏ស្ងៀមស្ងាត់ទៅវិញ”។

**ពួកគេនៅតែបន្តប្រឈមនឹងបញ្ហាដូចជា៖**

- ជំងឺរ៉ាំរ៉ៃ និងការទទួលបានសេវាថែទាំសុខភាពមិនគ្រប់គ្រាន់
- ជំងឺផ្លូវចិត្ត និងការបាត់បង់សមាជិកគ្រួសារ
- ការរើសអើង និងការផាត់ចេញពីការទទួលបានសេវាកម្មនានា
- កង្វះដីធ្លី និងភាពក្រីក្រដែលកាន់តែលំបាកខ្លាំងពេលវ័យកាន់តែជរា និងពិការភាព
- ការបាត់បង់ ឬខ្វះឯកសារអត្តសញ្ញាណស្របច្បាប់ ជាពិសេសចំពោះជនជាតិភាគតិចវៀតណាមដែលរស់នៅរយៈពេលយូរដោយគ្មានសញ្ជាតិ។

អ្នកផ្តល់បទសម្ភាសជាច្រើនបារម្ភថា ហិង្សាអាចនឹងកើតឡើងម្តងទៀត ដោយមានអ្នកផ្តល់បទសម្ភាសជាច្រើននិយាយថា៖ “ខ្ញុំខ្លាចថា វាអាចកើតឡើងម្តងទៀត”។ ភាពភ័យខ្លាចនេះជាការពិត ចំពោះពួកគាត់មួយចំនួន ព្រោះពួកគាត់បានចងចាំយ៉ាងច្បាស់អំពីការវាយប្រហារលើសហគមន៍របស់ពួកគាត់នៅចុងទសវត្សរ៍ឆ្នាំ៩០ ដោយខ្មែរក្រហម។

**អ្នករស់រានមានជីវិតទាំងនេះភ្ជាប់ការទប់ស្កាត់ជាមួយនឹង ឆន្ទៈទទួលខុសត្រូវ សមភាព យុត្តិធម៌សង្គម ការគោរពច្បាប់ និងការការពារជនជាតិភាគតិច ហើយពួកគេអំពាវនាវឲ្យ៖**

- ពង្រឹងច្បាប់នានា និងសិទ្ធិមនុស្ស ឲ្យស្មើភាពសម្រាប់មនុស្សគ្រប់រូប
- ដោះស្រាយអំពើពុករលួយ និងការរើសអើង
- បន្តការទាមទារយុត្តិធម៌ និងការអប់រំពីកំហុសពីអតីតកាល
- ការលើកដំកើងអភិបាលកិច្ច និងការផ្សះផ្សាប្រកបដោយបរិយាបន្នទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។

## ៤ ហេតុអ្វីចានជាការទប់ស្កាត់មានសារៈសំខាន់?

ការស្រាវជ្រាវជាសាកលបង្ហាញថា ហានិភ័យដែលបង្កឲ្យមានឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅតែមាន ប្រសិនបើយើងមិនយកដើមហេតុនៃអំពើហិង្សាមកដោះស្រាយ ឬដោះស្រាយមិនបានគ្រប់គ្រាន់។ ចំពោះជនជាតិភាគតិចដែលធ្លាប់រងការបំពានពីអតីតកាល រួមមានការផាត់ពួកគេចេញពីសង្គម និងច្បាប់ (រួមទាំងភាពគ្មានសញ្ជាតិ) ការខ្វះឱកាសទទួលបានសេវាសង្គម និងប្រកបរបរចិញ្ចឹមជីវិត និងការបង្ខំឱ្យផ្លាស់ទីលំនៅ ព្រមទាំងខ្វះការទទួលស្គាល់ ឬការការពារពីស្ថាប័នរដ្ឋ។

បើមិនដោះស្រាយហានិភ័យទាំងនេះ ក្រោយពី អ.វ.ត.ក. បានបញ្ចប់នោះទេ យុត្តិធម៌ជានិមិត្តរូបនឹងមិនអាចក្លាយជាយុត្តិធម៌ពិតប្រាកដបានឡើយ។ លក្ខខណ្ឌឫសគល់នៃការរើសអើង និងអំពើហិង្សានៅតែបន្តមាន ហើយរដ្ឋាភិបាល និងសង្គមកម្ពុជាកំពុងបាត់បង់ឱកាសសំខាន់ក្នុងការកសាងការផ្សះផ្សា និងលើកកម្ពស់ការទប់ស្កាត់អំពើឃោរឃៅ។

ការគាំទ្រអ្នករស់រានមានជីវិតជនជាតិភាគតិចដូចជា ខ្មែរក្រោម និងជនជាតិភាគតិចវៀតណាម មិនមែនជាការធ្វើសប្បុរសធម៌ទេ តែវាជាការការពារពួកគេ។ ការចូលរួមរបស់ពួកគេនាំឲ្យមានការពង្រឹងទំនុកចិត្តក្នុងសហគមន៍ ពង្រឹងសាមគ្គីភាពសង្គម ភាពស្របច្បាប់របស់រដ្ឋាភិបាលកម្ពុជា និងភាពធន់របស់ជាតិ។

## ៦ សន្និដ្ឋាន

ក្នុងអំឡុងពេលដែល អ.វ.ត.ក. ដំណើរការ អ្នកពាក់ព័ន្ធភាគច្រើនបានផ្តោតទៅលើអតីតកាល ដើម្បីផ្តល់យុត្តិធម៌ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ នៅខណៈដែល អ.វ.ត.ក. កំពុងបញ្ចប់ភារកិច្ចរបស់ខ្លួន នេះជាពេលដែលត្រូវមើលឆ្ពោះទៅមុខ និងប្រើប្រាស់កេរដំណែលរបស់តុលាការនេះ ដើម្បីបង្កើតសន្តិភាពប្រកបដោយចីរភាពនៅកម្ពុជា ដោយធ្វើយ៉ាងណាកុំឲ្យឧក្រិដ្ឋកម្មឃោរឃៅបែបនេះកើតឡើងម្តងទៀត។ វានឹងតម្រូវឲ្យមានការលើកស្ទួយការយល់ដឹង ការបង្កើនសមត្ថភាព និងការបង្កើតក្របខណ្ឌជាក់លាក់ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មនៅកម្ពុជា។

កម្មវិធីទប់ស្កាត់ឧក្រិដ្ឋកម្មពេញលេញ ត្រូវចាប់ផ្តើមពីការយល់ដឹងថា ក្រុមមនុស្សមួយចំនួនក្នុងសង្គមអាចមានភាពងាយរងគ្រោះជាងគេ(ផ្អែកលើជាតិពន្ធុ ពូជសាសន៍ ភេទ សាសនា ឬកត្តាផ្សេងៗ)។ ការបង្កើតយន្តការជាតិដែលគិតគូពីយេនឌ័រសម្រាប់ការទប់ស្កាត់អំពើឃោរឃៅ គឺជាគន្លឹះសំខាន់មួយដើម្បីធានាថា អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងៗ នឹងមិនកើតឡើងម្តងទៀត។ ការការពារជនជាតិភាគតិច មានតួនាទីសំខាន់ក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្ម ព្រោះពួកគេជាញឹកញាប់ច្រើនជាគោលដៅរបស់ឧក្រិដ្ឋកម្ម ដូចដែលបានកើតឡើងរួចមកហើយក្នុងរបបខ្មែរក្រហម។ ហេតុដូចនេះ ការរួមបញ្ចូលមតិយោបល់របស់ពួកគេក្នុងការបង្កើត និងអភិវឌ្ឍយន្តការថ្នាក់ជាតិ និងក្របខណ្ឌនានាមានសារៈសំខាន់ណាស់ដើម្បីអនុវត្តនូវវិធានការទប់ស្កាត់ឧក្រិដ្ឋកម្មនៅកម្រិតជាតិ។



អ្នករស់រានមានជីវិតជនជាតិខ្មែរក្រោម និងជាជនរងគ្រោះនៃការរៀបការដោយបង្ខំ មកពីខេត្តបាត់ដំបង បានបាត់បង់ឪពុក បងប្អូន និងសាច់ញាតិដទៃទៀតនៅក្នុងសម័យខ្មែរក្រហម។

## ៥ អ្វីនៅជាតម្រូវការរបស់អ្នករស់រានមានជីវិត?

អ្នករស់រានមានជីវិតបានកំណត់តម្រូវការសំខាន់ចំនួន ៥ ដូចខាងក្រោម

- **សេវាសុខភាព និងការគាំទ្រពីជំងឺរ៉ាំរ៉ៃ៖** អ្នករស់រានមានជីវិតជាច្រើនមានវ័យចំណាស់ ជាស្ត្រីមេម៉ាយ ឬមានពិការភាព ដែលជាលទ្ធផលនៃភាពរងទុក្ខនៅសម័យខ្មែរក្រហម។
- **ជំនួយដល់ជីវភាព៖** កញ្ចប់ថវិកាតូចមួយសម្រាប់សាងសង់លំនៅឋាន ការបង្កើតប្រាក់ចំណូល និងសុវត្ថិភាពអាហារ។
- **អត្តសញ្ញាណស្របច្បាប់ និងការផ្តល់សញ្ជាតិប្រកបដោយបរិយាបន្ន៖** ជនជាតិវៀតណាមដែលរស់នៅរយៈពេលវែង និងជនជាតិខ្មែរក្រោមខ្វះឯកសារអត្តសញ្ញាណស្របច្បាប់គ្រប់គ្រាន់ (មួយចំនួនបានរស់នៅក្នុងភាពគ្មានសញ្ជាតិជាច្រើនជំនាន់) ដែលជាហេតុធ្វើឲ្យពួកគេជួបឧបសគ្គក្នុងការទទួលបានសេវាសាធារណៈនានា ការអប់រំ និងការការពារដោយច្បាប់។
- **ការទទួលស្គាល់ និងការមិនរើសអើង៖** បន្តកិច្ចការប្រមូលចងក្រងឯកសារ និងទទួលស្គាល់អំពើឧក្រិដ្ឋកម្មលើជនជាតិភាគតិច ដូចជា ខ្មែរក្រោម និងវៀតណាម ក្នុងការចងចាំជាតិ និងការអប់រំពីប្រវត្តិសាស្ត្រនេះដល់ក្មេងជំនាន់ក្រោយ។
- **បន្តកិច្ចខិតខំរកយុត្តិធម៌ និងកិច្ចការទប់ស្កាត់៖** អ្នករស់រានមានជីវិតយល់ថាការកាត់ក្តីរបស់ អ.វ.ត.ក. បានបញ្ចប់ ប៉ុន្តែតម្រូវការ និងការរំពឹងទុករបស់ពួកគេទាក់ទងនឹងការស្វែងរកយុត្តិធម៌ និងការទប់ស្កាត់ឧក្រិដ្ឋកម្មនៅមិនទាន់បញ្ចប់នៅឡើយទេ ដូច្នេះ តម្រូវឲ្យមានការប្តេជ្ញា និងកិច្ចខិតខំប្រឹងប្រែងបន្តទៀត។